# CONSTRUCTION NOTICE

ខែវិច្ឆិកា ឆ្នាំ 2021

## ការសាងសង់ប្រព័ន្ធលូទឹកថ្មី ដើម្បីជួយទប់ស្កាត់ទឹកជំនន់នៅ South Park




**ការពិពណ៌នាអំពីគម្រោងសាងសង់**

ក្រសួងភ្លើងទឹកក្រុងស៊ីងថុល Seattle Public Utilities (SPU) និងក្រសួងដឹកជញ្ជូនក្រុងស៊ីងថុល (SDOT) កំពុងសហការគ្នាធ្វើការលើគម្រោងលូទឹកនិងសាងសង់ផ្លូវ នៅ South Park **ដើម្បីដោះស្រាយបញ្ហាទឹកជំនន់និងបញ្ហាប្រព័ន្ធលូទឹកនៅ South Park ។**

ផ្លូវនានានឹងត្រូវបានចាក់កៅស៊ូឡើងវិញ ហើយផ្លូវក្រួសមួយចំនួនទៀតនឹងត្រូវបានកែលម្អឱ្យទៅជាផ្លូវកៅស៊ូ។ កន្លែងខ្លះ គេនឹងធ្វើចិញ្ចើមផ្លូវដើរនិងដាំដើមឈើបន្ថែមនៅតាមដងផ្លូវ។

គម្រោងនេះនឹងដំឡើងបំពង់ទឹកនិងលូទឹកថ្មីដើម្បីជួយកាត់បន្ថយទឹកជំនន់និងទប់ស្កាត់ទឹកភ្លៀងឱ្យបានប្រសើរជាងមុន។ នៅពេលអនាគត ទឹកនេះនឹងត្រូវបង្ហូរទៅស្ថានីយ៍ទឹកដើម្បីសម្អាតមុនបង្ហូរចូលទៅក្នុងផ្លូវទឹកស្ទឹង Duwamish ដែលស្ថិតនៅជិតទីនោះ។

**ពេលវេលាសាងសង់**

គម្រោងសាងសង់នេះបានចាប់ផ្តើមនៅពាក់កណ្តាលខែតុលា ឆ្នាំ 2021។ ការសាងសង់នេះត្រូវបានគេរំពឹងថា នឹងបញ្ចប់នៅចុងឆ្នាំ 2022។

**ទីតាំង**

គម្រោងនេះស្ថិតនៅក្នុងតំបន់ឧស្សាហកម្មនៅ South Park ចន្លោះផ្លូវលេខ 2nd Ave S និងផ្លូវលេខ 8th Ave S លាតសន្ធឹងដល់ផ្លូវ S Holden St និងផ្លូវ S Monroe St ។

**ប្រជាជនរស់នៅ SOUTH PARK កន្លែងប្រកបអាជីវកម្ម និងអ្នកធ្វើដំណើរ អាចរំពឹងទុកថា**

- ការសាងសង់ចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ក្នុងអំឡុងពេលថ្ងៃ ចាប់ពីម៉ោងប្រហែល 7ព្រឹក ដល់ម៉ោង 4ល្ងាច។
- មានសំលេងពីការសាងសង់ ដីហុយ ខ្ទរដី និងសំលេងជីកកកាយដី និងការដឹកជញ្ជូន។
- មានចរាចរណ៍ សម្ភារៈនិងឧបករណ៍សាងសង់កាន់តែច្រើននៅទីនោះ។
- ផ្លូវចូលទៅកាន់ផ្ទះឯកជន ត្រូវបានរក្សាឱ្យនៅដដែល។
- ផ្លូវចូលទៅផ្ទះឯកជនប្រហែលជានឹងត្រូវបានបិទមួយរយៈពេលខ្លីក្នុងកំឡុងពេលសាងសង់។ ក្រសួងភ្លើងទឹកក្រុងស៊ីងថុល Seattle Public Utilities និងអ្នកម៉ៅការលើគម្រោងនេះនឹងសម្រុះសម្រួលជាមួយម្ចាស់ដីអំពីការបិទផ្លូវនេះ បើចាំបាច់។
- ផ្លូវចេញចូលនៅក្នុងតំបន់នោះ នឹងត្រូវបានរក្សាឱ្យនៅដដែលក្នុងកំឡុងពេលសាងសង់ដើម្បីទុកឱ្យអ្នករស់នៅ ធ្វើការ ឬទៅលេងតំបន់នោះអាចចេញចូលបាន។

**គេហទំព័រសម្រាប់ព័ត៌មានបន្ថែម៖** www.seattle.gov/utilities/neighborhood-projects/south-park-drainage

ទំនាក់ទំនង


Jason Sharpley អ្នកគ្រប់គ្រងគម្រោងសាងសង់
jason.sharpley@seattle.gov, (206) 498-8734


Seattle Public Utilities | Seattle Department of Transportation | The Levy to MOVE SEATTLE